# របាយការណ៍ប្រចាំត្រមាសទី២

(ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី២ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.៣៨៩.៣៦៨ | ៤.០៤៣.៥៣០ |
| បំណុលសរុប | ៣.៥៣៦.៨៩០ | ៣.២៣៨.០៣៨ |
| មូលធនសរុប | ៨៥២.៤៧៨ | ៨០៥.៤៩២ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី២ឆ្នាំ២០២៣** | **ត្រីមាសទី២ឆ្នាំ២០២២** |
| ចំណូលសរុប | ១០៤.២១៦ | ៧៨.១៤១ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ៣៨.០០០ | ២៧.៥៣១ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ៣១.០៤១ | ២១.៦៩៣ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៣៥.១៨១ | ២៣.២០៥ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ត្រីមាសទី២ឆ្នាំ២០២៣** | **ឆ្នាំ២០២២** |
| អនុបាតសាធនភាព ❶ | ១៩,៧៥ | ២១,៨១ |
| អនុបាតបំណុលធៀបនឹងមូលធន | ៤១៤,៩០ | ៤០២,០០ |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព ❶ | ១០៧,៤០ | ១២៧,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៥,១៧ | ៤,៦១ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០១,១៥ | ១០៥,០៣ |
| **អនុបាតផលចំណេញ(%)** | **ត្រីមាសទី២ឆ្នាំ២០២៣** | **ត្រីមាសទី២ឆ្នាំ២០២២** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) ❸ | ៣,២១ | ២,២៦ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) ❹ | ១៦,៥៥ | ១២,៣៩ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៨៧០,៧៦ | ៨៨៥,១៤ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶: អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷: ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

❸: អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម : លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ / ទ្រព្យសកម្មសរុប

❹: អនុបាតចំណេញធៀបនឹងមូលធន : លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ / មូលធនសរុប

*) លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទខ្ពស់ជាងចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ ដោយសារលម្អៀងពីការប្តូររូបិយប័ណ្ណ។

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ស្ថានភាពហិរញ្ញវត្ថុ (លានរៀល)




## លទ្ធផលហិរញ្ញវត្ថុ (លានរៀល)




## អនុបាតផលចំណេញ(%)



# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

អភិបាលប្រតិបត្តិ



**BANG, Keuk Bong**

អភិបាលប្រតិបត្តិ



**HONG, Jee Soo**

អភិបាលឯករាជ្យ



**LEE, Myunsang**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ដោយអនុវត្តតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

សេដ្ឋកិច្ចនៃប្រទេសកម្ពុជាកំពង់ឆ្ពោះទៅរកការស្ទុះងើបឡើងវិញ ដែលជម្រុញដោយការនាំចេញផលិតកម្ម និងកំណើននៃផ្នែកសេវាកម្ម និងវិស័យកសិកម្ម។ ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាបានឈរជើងយ៉ាងរឹងមាំក្នុងឆ្នាំ២០២២ ដែលមានអត្រាកំណើនពិតប្រាកដចំនួន៥,២%។ ភាពរឹងមាំនៃផ្នែកសេវាកម្ម ជាពិសេសវិស័យពាណិជ្ជកម្ម ការធ្វើដំណើរ និងបដិសណ្ឋារកិច្ចបានជួយធ្វើឱ្យប្រទេសកម្ពុជាដំណើរការជាធម្មតាដូចពេលមិនទាន់មានវិបត្តិកូវីដ១៩ ជាមួយនឹងវត្តមានជនបរទេសដែលបានមកដល់ប្រទេសកម្ពុជា ខណៈពេលដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកីឡាស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេម។ ស្ថានភាពនេះក៏ត្រូវបានជំរុញឲ្យមានការបន្ធូរបន្ថយតម្លៃក្នុងស្រុកនៅពេលដែលតម្លៃប្រេង និងអាហារក្នុងពិភពលោកមានស្ថិរភាព។ ជាមួយនឹងវិស័យកសិកម្មបានពង្រីកដោយសារតែការធ្វើឱ្យប្រសើរឡើងនូវការចូលទៅកាន់ទីផ្សារក្នុងតំបន់ បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលបានផ្តល់សច្ចាប័នថ្មីៗ នាំឲ្យកំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ៥,៥% នៅឆ្នាំ ២០២៣ ។

វិស័យធនាគារបានបន្តដើរតួនាទីជាប្រភពហិរញ្ញវត្ថុដ៏សំខាន់ក្នុងការផ្តល់ថាមពល ទៅដល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចដែលកំពុងងើបឡើងវិញនិងកំពុងត្រូវការធនធានហិរញ្ញវត្ថុ ដើម្បីបន្តជំរុញកំណើនសកម្មភាពសេដ្ឋកិច្ច។ ក្នុងដំណាក់កាលនៃការស្តារសេដ្ឋកិច្ចឡើងវិញ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានផ្តល់ឥណទានទៅកាន់វិស័យឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម ដែលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតឱកាសការងារ បង្កើនប្រាក់ចំណូលរបស់ប្រជាជន សំដៅដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិកក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំនិងភាពជាអ្នកដឹកនាំ បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្ត

អតិថិជនរបស់យើងទាំងអស់សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលបត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និង ការគាំទ្រ។

ជាចុងក្រោយ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ជាមួយនឹងការបន្តការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែង ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តរីកចម្រើន និងមានការអនុវត្តល្អបំផុតនៅឆ្នាំ២០២៣ ជាមួយនឹង សមិទ្ធផលនៃគោលដៅផ្សេងបន្ថែមទៀត។

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣

ហត្ថលេខា និងត្រា

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** .......... 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** .......... 2

**សមាសភាពក្រុមប្រឹក្សាភិបាល** .......... 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** .......... 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** .......... 7

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ .......... 7

ខ. លក្ខណៈនៃធុរកិច្ច .......... 8

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ .......... 9

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** .......... 11

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក .......... 11

ខ. រចនាសម្ព័ន្ធចំណូល .......... 11

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** .......... 12

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** .......... 13

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ .......... 13

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .......... 15

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល .......... 17

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ .......... 17

ង. ផលប៉ះពាល់អតិផរណា .......... 18

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល .......... 18

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** .......... 18

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូល | លោក Lee Jin Young |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្ដើមប្រតិបត្តិការធនាគារ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្ដាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្ដើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំគឺ Jeonbuk Bank Co.. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.). ក្រុមហ៊ុន Apro Financial Co.. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co.. Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co.. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co.. Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀត យើងក៏មិនភ្លេចនឹងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២៣ ទ្រព្យសកម្មសរុបរបស់យើងមានចំនួន ១,០៦៣ លានដុល្លារអាមេរិក មាន ២៣ សាខាទូទាំងប្រទេស និង ៦៦ ម៉ាស៊ីនATM និង ២ CRMs កំពុងដំណើរការនៅទូទាំងប្រទេស (ម៉ាស៊ីន ATM និង CRM ផ្សេងទៀតកំពុងត្រូវបានសិក្សាដើម្បីដំឡើងនៅតាមទីតាំងដែលមានសក្តានុពលទូទាំងប្រទេស)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តធ្វើការផ្ដល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្ដាញឌីជីថល(សេវាធនាគារចល័ត សេវាធនាគារតាមប្រព័ន្ធអ៊ិនធើណែត សេវាផ្ញើសារជូនដំណឹង) ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។ ក្រៅពីនេះយើងក៏បាននិងកំពុងបន្តបង្កើតផលិតផលនិងសេវាកម្មជាច្រើនទៀតដើម្បីបំពេញតម្រូវការរបស់អតិថិជនដូចជា សេវាទូទាត់ (កាតឥណពន្ធVisa កាតឥណទានVisa សេវាម៉ាស៊ីនឆូតកាត ការទទួលកាតVisaលើម៉ាស៊ីន ATM), ប្រាក់បញ្ញើ (គណនីសន្សំ គណនីចរន្ត គណនីមានកាលកំណត់ គណនីសន្សំថេរ), សេវាសម្ព័ន្ធភាពជាមួយភាគីទី៣

(វីង រដ្ឋករទឹកស្វយ័ត អគ្គីសនីកម្ពុជា បសស អេអឹមខេ ទ្រូម៉ាន់នី បញ្ជី បាគង ។ល។) សេវាឥណទាន (ឥណទានលំនៅដ្ឋាន ឥណទានរថយន្ត ឥណទានខ្នាតតូចនិងមធ្យម និងឥណទានពាណិជ្ជកម្ម ជាច្រើនទៀត) និងមានផលិតផលជាច្រើនទៀត (KHQR ហិរញ្ញប្បទានពាណិជ្ជកម្ម បើកប្រាក់បៀវត្ស ផ្ទេរប្រាក់ Western Union សេវាប្តូរប្រាក់ ។ល។)។

អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ live chat ២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញ ឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផល-សេវា របស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្នុងនាមជាធនាគារដែលផ្តោតលើការផ្តល់ភាពងាយស្រួលដល់អតិថិជន ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក តែងតែព្យាយាមក្នុងការពង្រីកបន្ថែមនូវសកម្មភាពប្រតិបត្តិការអាជីវកម្ម និងនាំមកនូវមធ្យោបាយកាន់តែប្រសើរសម្រាប់អតិថិជនដ៏មានតម្លៃរបស់យើង។

ដូច្នេះនៅថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០២៣ កម្មវិធី PPCBank Mobile App ផ្តល់នូវបច្ចេកវិទ្យាចុងក្រោយបំផុតជាមួយនឹងមុខងារជាច្រើនដើម្បីធ្វើឱ្យធនាគារកាន់តែមានសុវត្ថិភាពនិងទំនើប។ អតិថិជនអាចបើកគណនីរហ័សបានយ៉ាងងាយស្រួលនៅលើកម្មវិធីទូរស័ព្ទ ដើម្បីសម្រួលដល់ការទូទាត់ និងទទួលប្រាក់ភ្លាមៗពីគ្រប់ធនាគារទាំងអស់។

នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២៣ សម្រាប់ការប្រើប្រាស់ PPCBank Visa នៅលើកម្មវិធី TADA អតិថិជននឹងទទួលបានការធ្វើដំណើរដោយឥតគិតថ្លៃទៅកាន់ ឬមកពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងផ្សារទំនើបអ៊ីអនទាំង៣សាខា។

នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២៣ PPCBank បានរួមបញ្ចូល តេលេក្រាម Live Chat នៅលើគេហទំព័រ PPCBank, Mobile App, និង SmartBiz ដើម្បីអោយកាន់តែងាយស្រួលក្នុងការឆ្លើយតប និងដោះស្រាយបញ្ហាភ្លាមៗដល់អតិថិជន។

នៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២៣ ជាមួយនឹងមុខងារ Cardless Cash ថ្មី អតិថិជនអាចដកប្រាក់បានយ៉ាងងាយស្រួលពីម៉ាស៊ីន ATM របស់ PPCBank ដោយគ្មានកាត។ គ្រាន់តែចូលទៅក្នុងកម្មវិធី PPCBank Mobile ចូលទៅកាន់មុខងារ Cardless Cash នៅលើហ្វូមស្រ្តីនរួចបំពេញលេខទូរស័ព្ទ និងចំនួនទឹកប្រាក់ដែលត្រូវដក នោះអតិថិជននឹងទទួលបានលេខកូដដកប្រាក់ភ្លាមៗដោយមិនគិតថ្លៃ។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី២ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៩.៨២៩ | ៨.៨៣៧ |
| ឥណទានដុលសរុប (លានរៀល) | ៣.៣៧១.៧៦៦ | ៣.២០២.៩៨២ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៥៨.៦៨០ | ១៤៨.៣៨០ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣.២៦២.១៩៧ | ២.៩៧៤.១៨៣ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៥៩ | ៤៨៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៦៨ | ៧១ |
| ចំនួនម៉ាស៊ីនទូទាត់ | ២១៧ | ២១៥ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ឆ្នាំ២០២៣ | | ត្រីមាសទី២ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ១០១.៤១៦ | ៩៧,៣១ | ៧៥.៤៩៣ | ៩៦,៦១ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.៥៧៤ | ២,៤៧ | ២.៥៧៦ | ៣,៣០ |
| ៣ | ចំណូលផ្សេងៗ | ២២៦ | ០,២២ | ៧៣ | ០,០៩ |
| **ចំណូលសរុប** | | **១០៤.២១៦** | **១០០** | **៧៨.១៤១** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញ ដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជម.ក (PPCBank)និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co.. Ltd គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ឆ្នាំ២០២៣ | | ត្រីមាសទី២ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ១០១.៤១៦ | ៩៧,៣១ | ៧៥.៤៩៣ | ៩៦,៦១ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.៥៧៤ | ២,៤៧ | ២.៥៧៦ | ៣,៣០ |
| ៣ | ចំណូលផ្សេងៗ | ២២៦ | ០,២២ | ៧៣ | ០,០៩ |
| **ចំណូលសរុប** | | **១០៤.២១៦** | **១០០** | **៧៨.១៤១** | **១០០** |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៧% នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី២ ឆ្នាំ២០២៣។

## ៣. ការវិភាគតម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៍ចំនេញខាត | ត្រីមាសទី២ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១០១.៤១៦ | ៧៥.៤៩៣ | ២៥.៩២៤ | ៣៤,៣៤ |
| ចំណាយលើការប្រាក់ | (៣៥.៩៨៧) | (២៤.០៦៧) | (១១.៩២១) | ៤៩,៥៣ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៦៥.៤២៩** | **៥១.៤២៦** | **១៤.០០៣** | **២៧,២៣** |
| ចំណូលកម្រៃ និងជើងសារ | ២.៥៧៤ | ២.៥៧៦ | (២) | (០,០៩) |
| ចំណាយកម្រៃ និងជើងសារ | (៩៩៨) | (៧៤០) | (២៥៨) | ៣៤,៨៥ |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **១.៥៧៥** | **១.៨៣៦** | **(២៦០)** | **(១៤,១៨)** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២២៦ | ៧៣ | ១៥៣ | ២១០,៥២ |
| ចំណាយបុគ្គលិក | (៨.៥០២) | (៨.០៤២) | (៤៥៩) | ៥,៧១ |
| ចំណាយប្រតិបត្តិការ | (៦.៩០១) | (៨.៣២៣) | ១.៤២២ | (១៧,០៨) |
| ចំណាយរំលស់ | (៦.១៦៣) | (៦.៦៩៤) | ៥៣០ | (៧,៩២) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៤៥.៦៦៤** | **៣០.២៧៥** | **១៥.៣៨៩** | **៥០,៨៣** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (៧.៦៦៤) | (២.៧៤៤) | (៤.៩២០) | ១៧៩,៣៣ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៣៨.០០០** | **២៧.៥៣១** | **១០.៤៦៩** | **៣៨,០២** |

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ៣៨.០០០លានរៀល (៣៨% ច្រើនជាងប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២២) ។ ការកើនឡើងនៃប្រាក់ចំណេញគឺដោយសារការកើនឡើងនៃចំណូលការប្រាក់លើឥណទាន។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី២ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣៨.០០០ | ២៧.៥៣១ | ១០.៤៦៩ | ៣៨,០២ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៦.៩៥៨) | (៥.៨៣៩) | (១.១២០) | ១៩,១៨ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | ៣១.០៤១ | ២១.៦៩៣ | ៩.៣៤៩ | ៤៣,១០ |

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ៣១.០៤១លានរៀល ដែលបានកើនឡើង ៤៣% ប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២២ ការកើនឡើងនេះមកពីការប្រែលប្រួលដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី២ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ៣១.០៤១ | ២១.៦៩៣ | ៩.៣៤៩ | ៤៣,១០ |
| ការខាតលម្អិតផ្សេងៗ | ៤.១៣៩ | ១.៥១២ | ២.៦២៧ | ១៧៣,៧០ |
| **ប្រាក់ចំណេញលម្អិតសរុប** | ៣៥.១៨១ | ២៣.២០៥ | ១១.៩៧៦ | ៥១,៦១ |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

សញ្ញាជាបណ្តោះអាសន្ននៅដើមឆ្នាំ ២០២៣ ដែលសេដ្ឋកិច្ចពិភពលោកអាចសម្រេចបាននោះគឺនូវមានភាពទន់ខ្សោយនៅឡើយ ជាមួយនឹងការថយចុះនៃអត្រាអតិផរណា និងកំណើនស្ថិរភាពបានធូរស្បើយទៅវិញ ដែលបង្កឡើងពីការកើនឡើងយ៉ាងខ្ពស់នៃអតិផរណា និងភាពចលាចលក្នុងវិស័យហិរញ្ញវត្ថុនាពេលថ្មីៗនេះ។ ទោះបីជាអតិផរណាបានធ្លាក់ចុះដោយសារធនាគារកណ្តាលបានដំឡើងអត្រាការប្រាក់ ហើយតម្លៃអាហារ និងថាមពលបានធ្លាក់ចុះក៏ដោយ តែសម្ពាធតម្លៃមូលដ្ឋានកំពុងបង្ហាញភាពស្អិតរមួតដោយទីផ្សារការងារមានភាពតឹងតែងនៅក្នុងសេដ្ឋកិច្ចមួយចំនួននៅឡើយ។ ផលប៉ះពាល់ពីការកើនឡើងយ៉ាងឆាប់រហ័សនៃអត្រាការប្រាក់គោលនយោបាយកំពុងលេចចេញជារូបរាងឡើង ដោយសារភាពងាយរងគ្រោះក្នុងវិស័យធនាគារបានផ្តោតជាសំខាន់ ហើយការភ័យខ្លាច

នៃការរាលដាលបានកើនឡើងពាសពេញវិស័យហិរញ្ញវត្ថុយ៉ាងទូលំទូលាយ រួមទាំងស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

ដូច្នេះ សកម្មភាពរបស់ធនាគារ អាចនឹងមានផលប៉ះពាល់ខ្លះៗ មកលើប្រតិបត្តិការហិរញ្ញវត្ថុ និងកម្រិតនៃប្រាក់ចំណេញរបស់ធនាគារក្នុងរយៈពេលខ្លីនេះ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ការរក្សាបាននូវកំណើនប្រកបដោយនិរន្តរភាពគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់គ្រប់ឧស្សាហកម្មទាំងអស់។ ធនាគារ PPCBank តែងតែពង្រីក និងអភិវឌ្ឍផលិតផល និងសេវាកម្មថ្មីៗ ដើម្បីរក្សាបាននូវកំណើន និងក្នុងពេលជាមួយគ្នានេះដែរ ដើម្បីផ្តល់ជូននូវសេវាកម្មលឿនរហ័ស និងងាយស្រួលដល់អតិថិជនរបស់យើង។ ខាងក្រោមនេះគឺជាផលិតផល និងសេវាកម្មដែលបានពង្រីកបន្ថែម និងដាក់ឲ្យដំណើរការនាពេលថ្មីៗនេះ៖

- កម្មវិធី PPCBank Mobile App ផ្តល់នូវបច្ចេកវិទ្យាចុងក្រោយបំផុតជាមួយនឹងមុខងារជាច្រើនដើម្បីធ្វើឱ្យធនាគារកាន់តែមានសុវត្ថិភាពនិងទំនើប។ អតិថិជនអាចបើកគណនីរហ័សបានយ៉ាងងាយស្រួលនៅលើកម្មវិធីទូរស័ព្ទ ដើម្បីសម្រួល ដល់ការទូទាត់ និងទទួលបានសាច់ប្រាក់ភ្លាមៗពីគ្រប់ធនាគារទាំងអស់។
- PPCBank បានរួមបញ្ចូល តេលេក្រាម Live Chat នៅលើគេហទំព័រ PPCBank, Mobile App, និង SmartBiz ដើម្បីអោយកាន់តែងាយស្រួលក្នុងការឆ្លើយតប និងដោះស្រាយបញ្ហាភ្លាមៗដល់អតិថិជនរបស់ខ្លួន។
- ជាមួយនឹងមុខងារ Cardless Cash ថ្មី អតិថិជនអាចដកប្រាក់បានយ៉ាងងាយស្រួលពីម៉ាស៊ីន ATM របស់ PPCBank ដោយគ្មានកាត។ គ្រាន់តែចូលទៅក្នុងកម្មវិធី PPCBank Mobile ចូលទៅកាន់មុខងារ Cardless Cash នៅលើហូមស្គ្រីនរួចបំពេញលេខទូរស័ព្ទ និងចំនួនទឹកប្រាក់ដែលត្រូវដក នោះអតិថិជននឹងទទួលបានលេខកូដដកប្រាក់ភ្លាមៗដោយមិនគិតថ្លៃ។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

**៣. ការវិភាគលើពន្ធ**

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "**មាស**" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២២ និង២០២៣។

**៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

សេដ្ឋកិច្ចពិភពលោកកំពុងមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំពេលពីការកើនឡើងនៃអតិផរណា អាចនឹងមានផលប៉ះពាល់ខ្លះដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ធនាគារភ្នំពេញពាណិជ្ជ មានការកើនឡើងនៃចំណូល ដែលមានចំណូលការប្រាក់សុទ្ធសរុប ៦៥.៤២៩លានរៀល ដែលស្មើនឹងការកើនឡើង ២៧% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២២។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញាត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

ជាមួយអត្រាអតិផរណាបច្ចុប្បន្ន នឹងមិនមានផលប៉ះពាល់ណាមួយជាសារវន្តមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារនៅឡើយទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

នាពេលថ្មីៗនេះធនាគារជាតិ នៃកម្ពុជា បានចេញប្រកាសពីរទាក់ទងនឹងដើមទុនដូចខាងក្រោម៖

១ - ប្រកាស ស្តីពី ដើមទុនបទបញ្ញត្តិរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ប្រកាសនេះមានគោលបំណងកំណត់រចនាសម្ព័ន្ធ សមាសធាតុ និងវិធីសាស្ត្រគណនាដើមទុនបទបញ្ញត្តិរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ សំដៅពង្រឹងទាំងបរិមាណ និងគុណភាពនៃដើមទុន ដើម្បីរ៉ាប់រងការខាតបង់ ក្នុងករណីអាជីវកម្មកំពុងដំណើរការ (Going-concern) និងទូទាត់សងបំណុលនានា ក្នុងករណីអាជីវកម្មកំពុងស្ថិតក្នុងការជម្រះបញ្ជី ឬឈានទៅរកការជម្រះបញ្ជី (Gone-concern)។

២ - ប្រកាស ស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ប្រកាសនេះមានគោលបំណងផ្តល់វិធានសម្រាប់វាស់វែងហានិភ័យឥណទានក្នុងការអនុវត្តក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុន។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣

បានអាន និងឯកភាព




លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank